**ខ្លឹមសារសង្ខេបនៃប្រកាសលេខ៨៣៨ សហវ.ប្រក ចុះថ្ងៃទី២០/០៧/១៥**
**ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា**
**នៃក្រសួង ស្ថាប័នថវិកាកម្មវិធី**

- គោលបំណងនិងគោលដៅនៃប្រកាសនេះ គឺដើម្បីកំណត់វិធាននិងនីតិវិធីចំណាយសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ឱ្យបានទាន់ពេលវេលាតាមផែនការសកម្មភាពនៃកម្មវិធីរបស់ក្រសួង ស្ថាប័នថវិកាកម្មវិធី
- កំណត់ពាក្យបច្ចេកស័ព្ទកំណត់និយមន័យ ក្នុងក្របខណ្ឌប្រកាសនេះ ដូចខាងក្រោម÷
    - <u>*ក្រសួង ស្ថាប័នថវិកាកម្មវិធី÷*</u> ក្រសួង ស្ថាប័នទាំងឡាយណាដែលរាជរដ្ឋាភិបាលសម្រេចឱ្យអនុវត្តថវិកាកម្មវិធី
    - <u>*វគ្គបណ្តុះបណ្តាល÷*</u> សកម្មភាពនៃការផ្តល់ចំណេះដឹង ឬជំនាញជាក់លាក់ណាមួយក្នុងគោលដៅអភិវឌ្ឍសមត្ថភាព
    - <u>*សិក្ខាសាលា÷*</u> សកម្មភាពនៃការផ្សព្វផ្សាយ ការពិគ្រោះយោបល់ ការណែនាំ ឬ ការផ្លាស់ប្តូរបទពិសោធន៍។
- មុខសញ្ញាចំណាយ និងគោលការណ៍ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា រួមមាន÷
    - **ឯកសារនិងសម្ភារៈ** ÷ ផ្តល់ជូនក្នុងកម្រិតមិនលើសពី**៤០ ០០០រៀល/១នាក់/១វគ្គ**
    - **ការជួលទីតាំង, ការរៀបចំទីកន្លែង, ការរៀបចំអាហារ និងការឧបត្ថម្ភអ្នកចូលរួម** ត្រូវបានកំណត់ដូចខាងក្រោម÷
        - ក្នុងករណីប្រើប្រាស់ទីតាំងរបស់រដ្ឋ÷ ផ្តល់ជូនក្នុងកម្រិតមិនលើសពី៤០ ០០០រៀល/១នាក់/១ថ្ងៃ
        - ក្នុងករណីជួលទីតាំង÷ ផ្តល់ជូនក្នុងកម្រិតមិនលើសពី៦០ ០០០រៀល/១នាក់/១ថ្ងៃ។
    - **ការឧបត្ថម្ភគ្រូឧទ្ទេស**÷ ផ្តល់ជូន**៨០ ០០០រៀល/១ម៉ោង** សម្រាប់រយៈពេលកម្រិតអតិបរមាចំនួន៨ម៉ោង/១ថ្ងៃ
    - **ការឧបត្ថម្ភអ្នកសម្របសម្រួលនិងជំនួយការ** កំណត់ដូចខាងក្រោម÷
        - អ្នកសម្របសម្រួលផ្តល់ជូន៨០ ០០០រៀល/១នាក់/១ថ្ងៃ
        - ជំនួយការផ្តល់ជូន៤០ ០០០រៀល/១នាក់/១ថ្ងៃ
    - **ចំណាយផ្សេងៗ** ត្រូវផ្តល់ជូនក្នុងកម្រិត**មិនលើសពី៥%** នៃចំណាយសរុបខាងលើ។
- ឥណទានថវិកាសម្រាប់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា <u>**អាចអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន១០០%**</u> ហើយខ្ទង់ឥណទានចំណាយសម្រាប់មុខសញ្ញាចំណាយខាងលើ ត្រូវបានកំណត់ដូចខាងក្រោម÷
    - **វគ្គបណ្តុះបណ្តាល** ប្រើប្រាស់**គណនី៦១០៤** **"សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុងនិងក្រៅប្រទេស"**
    - **សិក្ខាសាលា** ប្រើប្រាស់**អនុគណនី៦១១០៣** **"ចំណាយសម្រាប់ប្រជុំ សិក្ខាសាលា សន្និសីទ"**។

    *(កន្លងមក គឺតម្រូវឱ្យញែកបំបែកខ្ទង់ចំណាយទៅតាមមុខសញ្ញាចំណាយ ដូចជា÷ ការទិញសម្ភារៈប្រើប្រាស់ជំពូក៦០, ចំណាយលើការជួលនិងរៀបចំ ប្រើប្រាស់ជំពូក៦១, និងការឧបត្ថម្ភ ប្រើប្រាស់ជំពូក៦៤ ជាដើម។ ចំពោះ ការអនុញ្ញាតឱ្យអនុវត្តចំណាយលើវគ្គបណ្តុះបណ្តាល ឬ សិក្ខាសាលា តាមនីតិវិធីរដ្ឋទេយ្យ. ១០០% គឺផ្តល់លទ្ធភាពងាយស្រួលដល់ក្រសួង ស្ថាប័នថវិកាកម្មវិធី ក្នុងការអនុវត្តសកម្មភាពនៃថវិកាកម្មវិធី បានរលូន និងទាន់ពេលវេលា ដោយមានសាច់ប្រាក់មុនក្នុងបេឡាគ្រប់គ្រាន់សម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន)*
- ចំណាយបេសកកម្មដែលបម្រើឱ្យសកម្មភាពបណ្តុះបណ្តាល ឬ សិក្ខាសាលា គឺត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់អំពីវិធាននិងនីតិវិធីដែលពាក់ព័ន្ធនឹងបេសកកម្ម។
- សក្ខីបត្រដើម ត្រូវរក្សានៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬ អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធ ដើម្បីជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្មជាក្រោយ។ អាណត្តិនិយ័តកម្ម គឺតម្រូវឱ្យភ្ជាប់តែរបាយការណ៍ចំណាយប៉ុណ្ណោះ។